សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# ផ្ញើជូន

## ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*ឯកឧត្តម ជាទីស្រឡាញ់រាប់អាន !*

ខ្ញុំបានទទួលរួចហើយ លិខិតជូនពររបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលបានផ្ញើមកជូនខ្ញុំនាពេលថ្មីៗនេះ ។ ក្នុងនាមភរិយាខ្ញុំ ខ្ញុំសូមថ្លែងអំណរគុណប្រកបដោយក្តីសោមនស្សរីករាយយ៉ាងក្រៃលែងចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានជូននូវសព្ទសាធុការពរបវរមហាប្រសើរចំពោះរូបខ្ញុំ និងភរិយា ព្រមទាំងក្រុមគ្រួសារ ក្នុងឱកាសខួបកំណើតគំរប់ ៥៨ ឈានចូល ៥៩ ឆ្នាំ របស់ខ្ញុំ នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៩ នេះ និងពរជ័យសិរីសួស្តីជ័យមង្គល ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំឆ្លូវ ឯកស័ក ព.ស. ២៥៥៣ ដែលនឹងឈានចូល ក្នុងពេលឆាប់ៗខាងមុខនេះ ។

តបចំពោះសមានចិត្ត និងពាក្យពេចន៍ពរជ័យដ៏មានអត្ថន័យប្រសើរថ្លៃថ្លានេះដែរ ជាថ្មីម្តងទៀត ក្នុងនាមភរិយាខ្ញុំ ខ្ញុំសូមប្រសិទ្ធពរជ័យជូនចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងក្រុមគ្រួសារ សូមទេវតារក្សាឆ្នាំថ្មី ព្រះនាម **រាក្សសាទេវី** តាមជួយបីបាច់ថែរក្សាឱ្យបានប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

*រាជធានីភ្នំពេញ ថ្ងៃទី* ០៣ *ខែ មេសា ឆ្នាំ ២០០៩*

ហ៊ុន សែន